**ខ្លឹមសារសង្ខេប**

**ស្តីពី**

**ច្បាប់គ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស**

**(២០១៦)**

**១.** ច្បាប់នេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពក្នុងការផ្សាំ កោសិកា ឬប្តូរសរីរាង្គ (មាត្រា១)។ កោសិកាសំដៅលើឯកតាតូចបំផុត ផ្គុំជាជាលិកា ហើយជាលិកា បង្កបង្កើតជាសរីរាង្គ។ សរីរាង្គជាច្រើន ផ្គុំក្លាយជាសារពាង្គកាយមនុស្ស (មាត្រា៤)។ ក្រសួងសុខាភិបាល មានសមត្ថកិច្ចក្នុងកិច្ចការងារនេះ និងផ្តល់ការអនុញ្ញាតដល់មន្ទីរពេទ្យដើម្បីបំពេញកិច្ចការងារបរិច្ចាគ ឬផ្សាំកោសិកា។ នៅក្រោមក្រសួង មានគណៈកម្មាធិការ (រៀបចំដោយប្រកាស) ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ លើមន្ទីរពេទ្យ ក្នុងការបរិច្ចាគ កោសិកា...(មាត្រា ៥)។ បន្ថែមពីលើនេះ មានគណៈកម្មការសម្រាប់ផ្សាំកោសិកា..(មាត្រា ៩) ដែលមន្ទីរពេទ្យនីមួយៗ ត្រូវបង្កើត (មាត្រា ១៦)។

**២.** ការបរិច្ចាគ ឬទទួល ផ្អែកតាមនុស្សធម៌ ស្ម័គ្រចិត្ត សុវត្ថិភាពភាគីទាំងពីរ និងការរក្សាការសម្ងាត់ (មាត្រា ៦)។ ការព្រមព្រៀងបរិច្ចាគ ត្រូវធ្វើជាលាយលក្ខអក្សរ (មាត្រា ៩)។ អ្នកផ្តល់ត្រូវតែជាមនុស្សមានអាយុយ៉ាងតិច ១៨ឆ្នាំ (មាត្រា ៧) ត្រូវទទួលសេវាព្យាបាល មុន ក្នុងអំឡុង និងក្រោយពេលបរិច្ចាគ។ បុគ្គលដែលចង់ទទួល សរីរាង្គ ...និងគ្មានការព្រមព្រៀងជាមុន ត្រូវចុះឈ្មោះក្នុងបញ្ជីរងចាំ (បែបបទ ត្រូវប្រកាសរបស់រដ្ឋមន្ត្រីសុខាភិបាល) (មាត្រា ១១)។ មុនការយល់ព្រមផ្តល់ ត្រូវមានការប្រាប់ឲ្យដឹងអំពីផលវិបាកពាក់ព័ន្ធ ហើយ អ្នកប្រកបវិជ្ជាជីវៈ ត្រូវពន្យល់ឲ្យច្បាស់ (មាត្រា ១២)។ នេះក៏ស្រដៀងគ្នាចំពោះអ្នកទទួលសរីរាង្គ...ផងដែរ (មាត្រា ១៣)។ ចំណាយលើការថែទាំសុខភាព សុខុមាលភាព មុន អំឡុងពេល និងក្រោយ ពេលបរិច្ចាគ ជាបន្ទុករបស់មន្ទីរពេទ្យ ដែលធ្វើការផ្សាំកោសិកា ...(មាត្រា ១០)។

**៣.** ទោសទណ្ឌ ត្រូវបានផ្តល់ចំពោះទង្វើរបស់បុគ្គល ឬនីតិបុគ្គល (មន្ទីរពេទ្យ) ចំពោះ ការធ្វើអាជីវកម្ម គ្មានការអនុញ្ញាត (មាត្រា ២០) ការដកហូតសរីរាង្គពីមនុស្សវិកលចរិត ទោះបីអាណាព្យាបាលឯកភាពក្តី (មាត្រា ២១) ការផ្តល់ ដោយសារការល្បួងលោម ឬព្រមដោយគ្មានជាលាយលក្ខណ៍អក្សរ (មាត្រា ២២) ធ្វើក្នុងបំណងពាណិជ្ជកម្ម

(មាត្រា ២៣) ផ្សាយពាណិជ្ជកម្ម (មាត្រា ២៤) មិនបានណែនាំអំពីផលវិបាកកើតមាន (មាត្រា ២៥, ២៦ និង ២៧)។ នីតិបុគ្គលទទួលខុសត្រូវចំពោះការបំពាន មាត្រា ២០, ២១, ២២, ២៣, ២៤, ២៥, ២៦ និង ២៧។ ទាំងបុគ្គល និងនីតិបុគ្គល អាចមានទោសបន្ថែម តាមច្បាប់ព្រហ្មទណ្ឌ។ អ្វីជាកត់សំគាល់ពិន័យ សម្រាប់នីតិបុគ្គល ច្រើនជាង រូបវន្តបុគ្គល។ ជាក់ស្តែងក្នុងករណីបំពានមាត្រា ២០ នីតិបុគ្គលនឹងទទួលពិន័យពី ១០ លាន ទៅ ៥០ លានរៀល (មាត្រា ៣០) ខណៈរូបវន្តបុគ្គល ត្រូវបង់ពិន័យពី ២ លាន ទៅ ៦ លានរៀល (មាត្រា ២០)។ បុគ្គលប្រព្រឹត្តល្មើស ក៏អាចទទួលទោសដាក់ពន្ធនាគារផងដែរ ដែលអាចយូរឬឆាប់ ទៅតាមផលវិបាកនៃអំពើ។ ឧទាហរណ៍ កាលបើអំពើ នាំឲ្យមានពិការភាពជាអចិន្ត្រៃយ៍ ....មានទោសពី១០ ទៅ ២០ ឆ្នាំ (មាត្រា ២១)។

**កំណត់សំគាល់**៖ ច្បាប់នេះ ចែងអំពី សិទ្ធិរបស់ អ្នកផ្តល់ និងអ្នកទទួលសរីរាង្គ បាននូវការថែទាំមុន ក្នុង អំឡុងពេល ឬ ក្រោយប្រតិបត្តិការប្តូរសរីរាង្គ។ ដូចគ្នានេះដែរ អ្នកប្រកបរបរវិជ្ជាជីវៈក្នុងវិស័យនេះ ក៏មានករណីកិច្ច និងទទួលខុសត្រូវផងដែរ។ ក្នុងករណី ប្រព្រឹត្តសកម្មភាពវេជ្ជសាស្ត្រខុសបច្ចេកទេស (Medical Malpractice) អាចទទួលខុសត្រូវក្រៅកិច្ចសន្យា ឬព្រហ្មទណ្ឌ។ អាស្រ័យហេតុនេះ បុគ្គលពាក់ព័ន្ធ ត្រូវដឹងអំពីសិទ្ធិ ដើម្បីទាមទារ ឬ បង្ការកុំឲ្យមានការបំពាន និងជៀសបាននូវទង្វើខុសច្បាប់ ដែលនាំឲ្យមានការទទួលខុសត្រូវ។